# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមហ៊ុន សាន់ ស៊ូ ហ្គាម៉ិន ខូអិលធីឌី**

# កិច្ចព្រមព្រៀង

## ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល២៣ថ្ងៃ

ថ្ងៃចន្ទ ៧កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹង ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង ០២:០០ នាទីរសៀល មានកិច្ចប្រជុំមួយនៅរោងចក្រ សាន់ ស៊ូ ហ្គាម៉ិន ខូអិលធីឌី មានអាសយដ្ឋានស្ថិតនៅភូមិ កប្បាស ឃុំខ្វិតធំ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដោយមានលោក HUANG HUNG LIN ជានាយកក្រុមហ៊ុន បានបើកកិច្ចប្រជុំមួយជាមួយ លោក ធឹម ថា ជាប្រធានសហជីព និង បងប្អូនដែលជាប្រតិភូបុគ្គលិក ចំនួន ៣០ រូបផ្សេងទៀត ដែលតំណាងអោយកម្មករ កម្មការិនីសរុប ២៨៧៤ នាក់។

ជាកិច្ចចាប់ផ្តើមលោក HUANG HUNG LIN ជាប្រធានអង្គប្រជុំ បានមានមតិស្វាគមន៍ដល់បងប្អូនប្រតិភូមបុគ្គលិកទាំងអស់ដែលបានចូលរួម និងបានបើកកិច្ចពិភាក្សាអំពីការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតនៅផ្នែកព្រីនចំនួន៥៧នាក់សម្រាប់រយៈពេល ២៧ថ្ងៃដោយគឺចាប់ពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤ ដល់ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២៤ ដោយសារស្ថានភាពបញ្ជាទិញរបស់អតិថិជនមានការធ្លាក់ចុះយ៉ាងខ្លាំង។

ក្រោយការពិភាក្សាគ្នា រវាងភាគីតំណាងក្រុមហ៊ុន និង ប្រតិភូបុគ្គលិក រួចមក ភាគីទាំងពីរបានឯកភាពផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតម្នាក់ៗចំនួន ៤៥ដុល្លារ រក្សាប្រាក់រង្វាន់ទៀងទាត់(ព្រីន)ព្រមទាំងប្រាក់ធ្វើដំណើរ ក្នុងកំឡុងពេលនៃការព្យួរនេះនិង បើកជូនបងប្អូនកម្មករ និយោជិតនៅ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤។

កិច្ចពិភាក្សាបានបញ្ចប់ នៅវេលាម៉ោង ០២:៤៥នាទីរសៀលនៅថ្ងៃខែឆ្នាំដដែល ក្រោមស្មាតីយោគយល់គ្នា និង ទទួលយកនូវស្មារតីនៃកិច្ចព្រមព្រៀងនេះ។

ថ្ងៃចន្ទ ៧កើត ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៤

**ភាគីទាំងពីរបានឯកភាព និង ផ្តិតមេដៃទុកជាភស្តុតាង**

**ប្រតិភូបុគ្គលិក** | **តំណាងក្រុមហ៊ុន**

ធឹម ថា | ជា គឹមឡាត់ | វ៉េង ណារ៉ា

**លោក** HUANG HUNG LIN

| | | | |
|---|---|---|---|
| ទឹម ម៉េងអ៊ី | ជួន សេងហួរ | ផៃ ស្រីនាង | ជុះ ឃុនស្រីពៅ |
| ម៉ម ប៉ូឡូ | ស៊ុន សុខវ៉េន | ម៉េស ស្រីមុំ | លី ចាន់ថា |
| ធឹម ធី | ឃីម ណាក់ | ភោគ ថាវី | សាំ ចាន់នី |
| ធន ណាំគ្រឿន | គូ ចំរើន | ចាន់ ដាលីន | គីម ធីម |
| ជុំ សិលា | ចុល សៅ | ថេន ដានី | ថៃ សុផល |
| ចែម រ៉ា | ជឿន ស្រីល័ក្ខ | មួន ណារ៉េន | យ៉ាន់ រស្មី |
| ស៊ឹម ស្រីម៉ៅ | ឃីម ធី | ជុំ ចន្ទី | ម៉ន ចាន់បូផា |

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
សាន់ ស៊ូ ហ្គាម៉ិន
SUN HSU GARMENT
Co.,Ltd
KINGDOM OF CAMBODIA